# តើអ្នកដឹងទេ?

## 1 - វិសាលភាព និងផលប៉ះពាល់នៃអំពើជួញដូរមនុស្ស

- អំពើជួញដូរមនុស្ស បានបំផ្លាញដល់សន្តិសុខមនុស្សជាតិ ដោយការកេងប្រវ័ញ្ច និងរំលោភបំពានលើសិទ្ធិ អាយុជីវិត កិត្តិយស សេចក្តីថ្លៃថ្នូរ របស់មនុស្ស ដែលជាជនរងគ្រោះ ក្រុមគ្រួសារ និងសង្គមជាតិ ។
- ជនល្មើសជួញដូរមនុស្សកេងយកផលប្រយោជន៍ពីជនរងគ្រោះ ដោយចាត់ទុកថាជាទំនិញ និងជាទាសករសម័យទំនើប ដោយមិនគិតពីទុក្ខ វេទនា និងការខាតបង់របស់ជនរងគ្រោះ ។
- ពលរដ្ឋមួយចំនួន ទាំងបុរស ស្ត្រី យុវវ័យ និងកុមារក្លាយជាជនរងគ្រោះ ដោយសារតែបាន ជឿលង់តាមការសន្យាផ្តល់ផលប្រយោជន៍ ការលួងលោម ឬបង្ខិតបង្ខំ តាមគ្រប់មធ្យោបាយ របស់មេខ្យល់ ទាំងមិនដឹងថា ខ្លួនកំពុងតែចូលក្នុងសំណាញ់របស់ឧក្រិដ្ឋជនពិបាកនឹងដកថយ ។
- ពលករជាច្រើន ចេញទៅរកការងារធ្វើ និងយុវនារីខ្លះ ស្វែងរកគូស្រករនៅក្រៅប្រទេសតាមរយៈមេខ្យល់ ឬមិត្តភក្តិ តែត្រូវបានគេជួញដូរ ធ្វើទណ្ឌកម្ម ប្រមាថមាក់ងាយ មិនបានអ្វីក្រៅពី ខាតបង់ទ្រព្យសម្បត្តិ ពេលវេលា កិត្តិយស សេចក្តីថ្លៃថ្នូរ ខ្លះធ្លាក់ខ្លួនពិការ ជម្ងឺរ៉ាំរ៉ៃ ញៀនថ្នាំ ពិការ មានផ្ទៃពោះដោយគ្មានការទទួលខុសត្រូវ និងខ្លះបានបាត់បង់ជីវិត ។

## 2 - តើ "ការជួញដូរមនុស្ស" ជាអ្វី?

a. គឺជា ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងលាក់ខ្លួន ឬការទទួលយកមនុស្ស ដោយមធ្យោបាយគំរាមកំហែង ឬការប្រើកម្លាំង ឬ ការបង្ខិតបង្ខំតាមរូបភាពផ្សេងៗ ដូចជា ការចាប់ពង្រត់ ការក្លែងបន្លំ ការបោក បញ្ឆោត ការរំលោភលើអំណាច ឬតួនាទីទៅលើជនដែលងាយទទួលរងគ្រោះ ឬការផ្តល់ ឬការទទួលជាលុយកាក់ ឬផលកម្រៃផ្សេងៗដើម្បីឲ្យមានការយល់ព្រមពីអ្នកគ្រប់គ្រងលើជនម្នាក់ទៀត ក្នុងគោលបំណងដើម្បីធ្វើការ "កេងប្រវ័ញ្ច"។

b. ការកេងប្រវ័ញ្ច៖ ត្រូវរាប់បញ្ចូលជាអប្បបរមានូវ ការធ្វើអាជីវកម្មពេស្យាចារលើអ្នកដទៃ ឬការកេងប្រវ័ញ្ចផ្លូវភេទតាមរូបភាពផ្សេងទៀត ការងារដោយបង្ខំ ឬសេវាកម្មទាសភាព ឬការអនុវត្តដែលមានលក្ខណៈស្រដៀងគ្នា ទៅនឹងទាសភាពភាព ជាអ្នកបម្រើដាច់ថ្លៃ ឬការដកហូតសរីរាង្គ ជាដើម ។

c. ប្រសិនបើមធ្យោបាយណាមួយ ដែលមានចែងក្នុងវាក្យខ័ណ្ឌ (a) នៃមាត្រានេះ ត្រូវបានយកមកប្រើ ដោយជនជួញដូរមនុស្ស ដើម្បីកេងប្រវ័ញ្ច ទោះបីជាមានការយល់ព្រមពីជនរងគ្រោះក៏ដោយ ក៏ការយល់ព្រមនេះមិនអាចយកជាការបានឡើយ ។

d. ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងលាក់ខ្លួន ឬការទទួលយកកុមារ ក្នុងគោល បំណងធ្វើអាជីវកម្ម ត្រូវចាត់ទុកថាជា "ការជួញដូរមនុស្ស" ទោះបីជាអំពើនេះមិនជាប់ពាក់ព័ន្ធទៅនឹងមធ្យោ បាយណាមួយ ដែលមានចែងក្នុងវាក្យ ខ័ណ្ឌ (a) នៃមាត្រានេះក៏ដោយ

e. "កុមារ" មានន័យថាមនុស្សណាម្នាក់ ដែលមានអាយុក្រោម១៨ឆ្នាំ ។

## 3 - ការឆ្លើយតបរបស់រាជរដ្ឋាភិបាលកម្ពុជា

- ព្រះរាជាណាចក្រកម្ពុជា មានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការពារអនីតិជន ដែលបានអនុម័ត និងប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការ ដោយព្រះរាជក្រម លេខ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលកំណត់ការដាក់ទោសទណ្ឌធ្ងន់ធ្ងរ លើជនជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ និងអ្នកសមគំនិត ជាពិសេសដែលបានប្រព្រឹត្តទៅលើកុមារ (អនីតិជន)។
- យន្តការជាតិដែលត្រូវបានបង្កើតឡើង គឺ«គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ៖ គ.ជ.ប.ជ» មាន២២ ក្រសួង ស្ថាប័នចូលរួម ដឹកនាំដោយ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងមានអគ្គលេខាធិការដ្ឋានមួយ ចំណុះក្រសួងមហាផ្ទៃ ដឹកនាំដោយអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ និងមានអគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរង មួយចំនួន ។
- គ.ជ.ប.ជ មាន៦ ក្រុមការងារអន្តរក្រសួងស្ថាប័ន :
    1. ក្រុមការងារបង្ការទប់ស្កាត់ ដឹកនាំដោយ ក្រសួងអប់រំ យុវជន និងកីឡា
    2. ក្រុមការងារការពារជនរងគ្រោះ ដឹកនាំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
    3. ក្រុមការងារអនុវត្តច្បាប់ ដឹកនាំដោយអគ្គស្នងការដ្ឋាននគរបាលជាតិ
    4. ក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយក្រសួងយុត្តិធម៌
    5. ក្រុមការងារទេសន្តរប្រវេសន៍ ដឹកនាំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
    6. ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ ដឹកនាំដោយ ក្រសួងកិច្ចការនារី

- ផែនការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល៥ឆ្នាំ ២០១៤-២០១៨ ត្រូវបាន និងកំពុងអនុវត្ត នៅថ្នាក់ក្រោមជាតិ មានគណៈកម្មាធិការថ្នាក់ក្រោមជាតិ ដែលហៅថា គណៈកម្មាធិការរាជធានី ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.រ.ប.ជ) ដឹកនាំដោយអភិបាលរាជធានី គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ដឹកនាំដោយអភិបាលខេត្ត និងមានរចនាសម្ព័ន្ធរហូតដល់ឃុំសង្កាត់ ទូទាំងប្រទេស ។
- គ្រប់ករណី ដែលអ្នកសង្ស័យថាជាអំពើជួញដូរមនុស្ស៖ ជួញដូរពលកម្ម ឬជួញដូរផ្លូវភេទ ជាពិសេសលើស្ត្រី និងកុមារ សូមរាយការណ៍ទៅបណ្តាញនៃរចនាសម្ព័ន្ធគណៈកម្មាធិការជាតិគ្រប់ថ្នាក់ ឬតាមលេខទូរស័ព្ទ ១២៨៨ ឬ ០២៣ ៩៩៧៩១៩ ។

www.ncct.gov.kh